**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.....០០៣.......សហវ ស.ណ.ន

# សេចក្តីណែនាំ

ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង បង្កើនប្រសិទ្ធភាពការងារ សន្សំសំចៃ និងបញ្ចៀសបាតុភាពអសកម្មជាយថាហេតុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមណែនាំដល់គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពក្រោមចំណុះទាំងអស់ នៅថ្នាក់កណ្តាល និងរាជធានី ខេត្ត ដូចខាងក្រោម ៖

១-ពង្រឹងការអនុវត្ត "គោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង" តាមប្រកាសលេខ ១១០៩ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ឯកសារ "គោលនយោបាយស្តីពីការគ្រប់គ្រងផ្ទៃក្នុង" (គេហទំព័រ កសហវ www.mef.gov.kh ចូល Law and Regulation ចូល page 5) ។

២-អគ្គាធិការដ្ឋាន នាយកដ្ឋានលទ្ធកម្មសាធារណៈ និងនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចុះត្រួតពិនិត្យតាមគោលដៅនីមួយៗបានកំណត់ តែមួយដងក្នុងមួយឆ្នាំ និងក្នុងប្រតិភូតែមួយ ដោយមន្ត្រីអគ្គាធិការដ្ឋានជាប្រធានប្រតិភូ ហើយរៀបចំនិងប្រើប្រាស់របាយការណ៍ត្រួតពិនិត្យតែមួយ ។ អង្គភាពទាំងបីអាចជួយពិនិត្យបញ្ហាតាមសំណើឱ្យគ្នា ក្នុងករណីអង្គភាពណាមួយពុំបានចូលរួម ។

៣-បង្កើនការសន្សំសំចៃលើការប្រើប្រាស់៖ ឧបករណ៍អេឡិចត្រូនិក ពិសេសម៉ាស៊ីនថតចំលង និងម៉ាស៊ីនបោះពុម្ព ក្រដាស ទឹក អគ្គិសនី ទូរសព្ទ/ទូរសារ និងអ៊ិនធើនែត ។ កិច្ចសន្យាជាវសេវាបីចុងក្រោយ គួរសើរើបើមានចំណេញ ។

៤-ពង្រឹងមូលដ្ឋានទិន្នន័យ ពិពិធកម្មតារាងស្ថិតិ និងរៀបចំរបាយការណ៍វិភាគប្រចាំខែ ត្រីមាស ឆមាសនិងឆ្នាំ ។

៥-ពង្រឹងការងារបញ្ជីសារពើភណ្ឌ ពិសេសឱ្យគ្រសោបគ្រប់ចំនួនទ្រព្យសម្បត្តិ តំលៃ និងមានបច្ចុប្បន្នភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរសព្ទ ៖ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៖ ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com